ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

លេខ ៖ .....១៥៤៧.....អ.ជ.ប.ជ.អ/៧.៥

សេចក្តីសម្រេចចិត្ត
នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
លើកទី១ ឆ្នាំ២០១៧

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៧ បានដំណើរការរយៈពេលមួយព្រឹកពេញ នាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ នៅរមណីយដ្ឋានបឹងសំរឹទ្ធិ ខេត្តកំពង់ធំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ កិច្ចប្រជុំនេះមានការចូលរួមពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ទាំង២៥ និងដៃគូអភិវឌ្ឍន៍ រួមទាំងសង្គមស៊ីវិល សរុបប្រមាណចំនួន១៧០រូប។

នៅក្នុងបរិការណ៍នៃការទទួលបានជោគជ័យក្នុងការប្រយុទ្ធទប់ស្កាត់ការរីករាលដាល នៃមេរោគអេដស៍ និងជំងឺអេដស៍ក្នុងប្រទេសកម្ពុជាដែលមានការទទួលស្គាល់ពីសហគមន៍ជាតិ និងអន្តរជាតិ និងស្របពេលដែលមានការធ្លាក់ចុះយ៉ាងគំហុកនៃថវិកាជំនួយពីដៃគូអភិវឌ្ឍន៍ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៧ បានដំណើរការក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដោយមានការចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយនិងបានដាក់ចេញនូវសេចក្តីសម្រេចចិត្តដូចតទៅ៖

១. បន្តអនុវត្តដោយម៉ឺងម៉ាត់នូវផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ ឆ្នាំ២០១៥-២០២០ ដែលជាយុទ្ធសាស្ត្រជាតិតែមួយគត់សម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២. បន្តអនុវត្តគោលនយោបាយប្រាំពីរចំណុចក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ តាមលិខិតលេខ២០៤៨ សជណ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

៣. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងមហាផ្ទៃ ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងក្រសួងយុត្តិធម៌ បន្តជំរុញការផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងអំពីច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឱ្យបានទូលំទូលាយ។

៤. ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគណៈកម្មាធិការប្រយុទ្ធដំងឺអេដស៍ ត្រូវរៀបចំគម្រោងផែនការសកម្មភាពការងារប្រយុទ្ធនឹងជំងឺអេដស៍ ស្របតាមអាណត្តិការងាររៀងៗខ្លួន ដើម្បីធានានិរន្តរភាពនៃការឆ្លើយតបនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍។

៥. ក្រសួងផែនការត្រូវបន្តសហការជាមួយថ្នាក់ក្រោមជាតិ ដើម្បីបញ្ចូនទិន្នន័យមកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នូវចំនួនគ្រួសារមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ដែលក្រីក្រទទួលបានប័ណ្ណសមធម៌តាមបណ្តាឃុំ សង្កាត់ ក្នុងរាជធានី ខេត្តទាំង៨ ក្នុងឆ្នាំ២០១៦។ ចាត់តាំងឱ្យមានតំណាងអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ចូលរួមក្នុងដំណើរការចងក្រងបញ្ជីឈ្មោះនិងធ្វើសម្ភាសន៍សម្រាប់ឆ្នាំ២០១៧ និងឆ្នាំ២០១៨ ដោយបញ្ចូនកាលបរិច្ឆេទជាក់លាក់មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឱ្យបានមុនកាលកំណត់។

៦. គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្តត្រូវរៀបចំផែនការថវិកាគាំទ្រដល់សកម្មភាពការងារប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្របតាមអាណត្តិរបស់ខ្លួន។

៧. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តគាំទ្រការរៀបចំ និងវិភាជកញ្ចប់ថវិកាកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ដល់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ដើម្បីអនុវត្តសកម្មភាពរៀបចំផែនការសកម្មភាពការងារដែលបានកំណត់ក្នុងចំណុច៦ ក្នុងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធិភាព និងចីរភាព។

៨. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធបន្តពិនិត្យលទ្ធភាព និងបង្កើនប្រសិទ្ធភាពទាក់ទាញហិរញ្ញប្បទានក្រៅប្រទេស ដើម្បីឆ្លើយតបនឹងការវិនិយោគក្នុងការងារប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍។

៩. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល និងអង្គភាពពាក់ព័ន្ធត្រូវពិគ្រោះយោបល់ពិភាក្សាលើការបង្កើតគោលការណ៍ណែនាំស្តីពី ការប្រុងប្រយ័ត្នជាសកលចំពោះការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ ជាពិសេសក្នុងអំឡុងពេលវះកាត់ទូទៅ វះកាត់កែសម្ផស្ស ធ្វើធ្មេញ អប់សព សាក់ ឬការងារដទៃទៀតដែលប្រឈមនឹងការឆ្លង ។

១០. បន្តជំរុញការអនុវត្តនូវគោលការណ៍បីមួយ (យុទ្ធសាស្ត្រតែមួយ ស្ថាប័នសម្របសម្រួលតែមួយ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃតែមួយ) ប្រកបដោយការទទួលខុសត្រូវខ្ពស់ ជាពិសេសធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃ តាមរយៈកិច្ចសហការនៃការផ្តល់ជារបាយការណ៍ជាប្រចាំអំពីការងារប្រយុទ្ធនឹងជំងឺអេដស៍ ពីស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីជាព័ត៌មានដ៏សំខាន់ក្នុងការវិភាជថវិកាចំគោលដៅអាទិភាពកាត់បន្ថយសកម្មភាពត្រួតគ្នា ធានាការប្រើប្រាស់ថវិកាប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ឆ្លើយតបទៅនឹងនិន្នាការនៃការធ្លាក់ចុះថវិកាជំនួយ។

១១. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវបង្កើន និងរិះរកវិធីសាស្ត្រឱ្យមានប្រសិទ្ធភាពក្នុងការរួមគ្នាប្រយុទ្ធនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍។

១២. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បន្តតួនាទីដឹកនាំគ្រប់គ្រង សម្របសម្រួលការអនុវត្តនូវសេចក្តីសម្រេចចិត្តនេះឱ្យមានប្រសិទ្ធភាព ដើម្បីឆ្ពោះទៅសម្រេចបាននូវគោលដៅ៩៥-៩៥-៩៥ នៅឆ្នាំ ២០២៥ តាមពាក្យស្លោក "**ឆាប់ធ្វើតេស្តឈាម ឆាប់ព្យាបាល ឆ្ពោះទៅបញ្ចប់អេដស៍**"៕

កំពង់ធំ, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧

ប្រធានអង្គប្រជុំ

ទេសរដ្ឋមន្ត្រី

ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អៀង ម៉ូលី